# ព្រឹត្តិបត្រព័ត៌មានលេខ ០៨
## (កក្កដា - កញ្ញា ២០២៣)

# Newsletter Issue 08
## (July - September 2023)

**នៅក្នុងលេខនេះ | In this Issue**


- វឌ្ឍនភាពការធានាឥណទាន និងការស្ទង់មតិរបស់ PFIs
  Credit Guarantee Progress and PFIs Survey
- បទពិសោធន៍របស់លោក ជួ មករា ម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC
  Meet with Mr. Chua Makara, Business Owner Who Received a Loan Guaranteed by CGCC
- អត្ថបទស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងការធានាឥណទានរបស់ CGCC
  Understanding Guarantee Management System of CGCC

# មាតិកា | Contents


សេចក្តីផ្តើម | Introduction ---- 01

វឌ្ឍនភាពការធានាឥណទាន | Credit Guarantee Progress ---- 05

កិច្ចសហប្រតិបត្តិការ និងសកម្មភាពនានា | Cooperation and Activities ---- 10

ការស្វែងយល់អំពីការធានាឥណទាន | Understanding Credit Guarantee ---- 17

ដៃគូរបស់យើង | Our Partners ---- 23


# ក្រុមការងារព្រឹត្តិបត្រព័ត៌មាន | Newsletter Editorial Team

## រៀបរៀងដោយ | Prepared by:

| | |
|---|---|
| លោក ណូ លីដា<br>Mr. No Lida | អគ្គនាយករង<br>Deputy Chief Executive Officer |
| លោកស្រី ពិន ម៉ានីកា<br>Ms. Pin Manika | ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម<br>Manager of Marketing and Business Development |
| លោកស្រី សាន សុខរីណា<br>Ms. San Sokrina | ប្រធានការិយាល័យអភិវឌ្ឍន៍ផលិតផល<br>Manager of Product Development |
| កញ្ញា សន ឆវីវតី<br>Ms. Sorn Chhorvyvatey | អនុប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម<br>Deputy Manager of Marketing and Business Development |
| លោក សែ គីមវាសនា<br>Mr. Se Kimveasna | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទីផ្សារ និងទំនាក់ទំនង<br>Senior Executive of Marketing and Communication |
| លោក គីម ហេងបំណង<br>Mr. Kim Hengbomnorng | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទីផ្សារ និងយុទ្ធនាការ<br>Senior Executive of Marketing & Campaign |
| លោកស្រី សុខ ចរិយា<br>Ms. Sok Chakriya | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកទំនាក់ទំនង<br>Senior Executive of Relationship Management |

## ចូលរួមផ្តល់មាតិកាដោយ | Contributed Contents by:

| | |
|---|---|
| លោកស្រី គឹម ចាន់ថាវី<br>Ms. Kem Chanthavy | អនុប្រធានការិយាល័យលទ្ធកម្ម<br>Deputy Manager of Procurement |

## រចនាដោយ | Designed by:

| | |
|---|---|
| លោក នង សុគន្ធា<br>Mr. Nong Sokunthea | បុគ្គលិកជំនាញជាន់ខ្ពស់ផ្នែកមាតិកា និងរចនាក្រាហ្វិក<br>Senior Executive of Creative Contents and Graphic Designer |

## ត្រួតពិនិត្យដោយ | Reviewed by:

| | |
|---|---|
| លោក **KL Wong**<br>Mr. KL Wong | អគ្គនាយក<br>Chief Executive Officer |

# សេចក្តីផ្តើម | Introduction

## សាររបស់អគ្គនាយក | Message from CEO

The 3rd quarter has been an eventful one for us despite the challenges faced in the financial sector. US interest rates have been on the rise and that has resulted in higher costs of lending. Loans became more costly to the MSMEs. Higher inflation and global oil prices have impacted overall economic activities. Regional economies have showed signs of slowdown which impacted foreign investments, tourism and demand for goods in the country. During this quarter, we noted that loan defaults were on the rise and non-performing loans (NPL) also increased. FIs are facing liquidity issues due to the higher costs of funding and higher NPLs. Our guarantee performance slowed down for these 3 months, recorded the lowest guarantee issuance as compared to the 1st two quarters ie. ***196 guarantees amounting to $16.2mil.***

On a positive note, in early July, the National Bank of Cambodia stated that guaranteed loans by CGCC will carry a ***zero-risk weight*** in computing their capital adequacy ratios effective 2024 onwards. This regulation will further add value to our guarantees to our PFIs. The credit guarantee will benefit the PFIs, not only for risk sharing but also for capital management of the PFI.

Another positive milestone for us was in August, when CGCC was accredited by the Securities and Exchange Regulator of Cambodia to be the ***1st Bond Guarantee Institution in Cambodia!*** This recognition gives us the opportunity to play a part in supporting the development of the bond market in the Cambodia Securities Exchange (CSX). CGCC will be able to guarantee corporate bonds listed on the CSX, to attract foreign investors to invest in corporate bonds and enable private sector companies to raise bonds as an alternative to get funds for their business.

In September, the accomplishments of CGCC have been recognized by the SME Finance Forum with an ***Honorable Mention in the "Product Innovation of the Year"*** category of the Global SME Finance Awards 2023, endorsed by the G20's Global Partnership for Financial Inclusion, honoring the institutions for their innovative products for SMEs with impressive results in expanding financing to SMEs. We are honored to receive this global recognition for the work we have put in to develop CGCC for the benefit of the MSMEs in Cambodia.

Another milestone we achieved was the ***launch of our Guarantee Management System (GMS)***, our digital platform for processing guarantees between CGCC and PFIs. The GMS also stores the guarantee database, automates billing of fees and for claim submissions, which is rolled out in phases. This is part of our digital journey to simplify the guarantee process.

We managed to structure 3 Portfolio Guarantee Schemes (PGS) for Prince Bank, Canadia Bank and Sathapana Bank. The PGS was customized for the banks' targeted segment of SMEs eg. women entrepreneurs, targeted retail and wholesale traders and tourist agents respectively. This makes up to 4 PGS amounting to $10mil since we started PGS in January 2023.

We onboarded our 27th PFI ie. Branch of Kasikornbank (Phnom Penh), our first Thai bank as our partner. The signing event was held at our new extended office and was graced by our Chairman, H.E. Ros Seilava and H.E. Cherdkiat Atthakor, Ambassador of Thailand to Cambodia.




I had the opportunity to attend the ACSIC conference held at Ulaanbaatar, Mongolia with our Chairman. It was the annual conference where we got to meet our peers from Asia in the credit guarantee industry. Good insights and learnings from this conference.

Best wishes,
**KL Wong**
CEO

## អំពី ស.ធ.ក. | About CGCC

**សាជីវកម្មធានាឥណទានកម្ពុជា (CGCC)** គឺជាសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០។ CGCC ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

CGCC ត្រូវបានចុះបញ្ជីជាផ្លូវការនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ និងទទួលបានការគាំទ្របច្ចេកទេស ពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងមូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ (UNCDF)។ CGCC បានដាក់ឱ្យដំណើរការនូវគម្រោងធានាឥណទានដំបូង នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។

Credit Guarantee Corporation of Cambodia (CGCC) is a state-owned enterprise established by a Sub-Decree No. 140 ANKR. BK dated 01 September 2020. CGCC is operated under the technical and financial guidance of the Ministry of Economy and Finance (MEF).

CGCC was incorporated on 03 November 2020 and has been receiving technical support from Asian Development Bank (ADB), World Bank, and UN Capital Development Fund (UNCDF). CGCC launched the first guarantee scheme on 29 March 2021.

### ទស្សនវិស័យ | Vision

ក្លាយខ្លួនទៅជាស្ថាប័នធានាឥណទាននាំមុខគេនៅប្រទេសកម្ពុជា ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម។

To be the preferred credit guarantee institution in Cambodia to improve financial inclusion and develop the growth of SMEs.

### បេសសកម្ម | Mission

បេសកកម្មចម្បងរបស់ CGCC គឺផ្តល់ការធានាឥណទានលើកម្ចីដែលផ្តល់ឱ្យអាជីវកម្ម ដើម្បីចែករំលែកហានិភ័យជាមួយស្ថាប័នផ្តល់កម្ចី និងបង្កើនបរិយាបន្នហិរញ្ញវត្ថុ។

To provide credit guarantees to lenders on loans made to businesses based on international standards to share the risk with lenders and to improve financial inclusion.

## ប្រជាជនកម្ពុជាទៅចូលរួមបោះឆ្នោត | Cambodians go to Vote



KH ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ប្រជាជនកម្ពុជាបានអនុវត្តសិទ្ធិរបស់ខ្លួន ដើម្បីជ្រើសរើសថ្នាក់ដឹកនាំប្រទេស តាមរយៈការបោះឆ្នោតស្របតាមលទ្ធិប្រជាធិបតេយ្យ។ ជាលទ្ធផល កម្ពុជាទទួលបាននាយករដ្ឋមន្ត្រីថ្មីគឺ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ដែលនឹងដឹកនាំរាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។

EN On 23 July 2023, Cambodian people exercised our rights to choose our leader through the democratic election. As a result, Cambodia has got a new Prime Minister, Samdech Moha Bovor Thipadei Hun Manet, who will lead the Royal Government of Cambodia of the Seventh Legislature of the National Assembly.

## សមិទ្ធផលសំខាន់ៗ | CGCC's Milestones

### ១ កញ្ញា ២០២០
ទទួលបានការអនុម័តលើអនុក្រឹត្យស្តីពីការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

### ៣ វិច្ឆិកា ២០២០
បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

### ៤ កុម្ភៈ ២០២១
ទទួលបានដើមទុនដំបូងចំនួន ៨១០ប៊ីលានរៀល (សមមូលនឹងប្រមាណ ២០០លានដុល្លារ) ពីរាជរដ្ឋាភិបាល

### ២៩ មីនា ២០២១
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី១ ហៅថា "គម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម"

### ២៣ មេសា ២០២១
បានផ្តល់ការធានាឥណទានជាលើកដំបូងលើកម្ចីទំហំ ១លានដុល្លារ

### ២២ កញ្ញា ២០២១
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី២ ហៅថា "គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន"

### ៥ វិច្ឆិកា ២០២១
ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម (VAT) លើកម្រៃធានាឥណទាន

### ០១ មេសា ២០២២
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានទី៣ ហៅថា "គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី" ដែលមានទំហំទឹកប្រាក់ ៣០លានដុល្លារ

### ០១ មេសា ២០២២
បានផ្លាស់មកកាន់ការិយាល័យថ្មី ដែលស្ថិតនៅជាន់ទី១៩នៃមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច

### ១២ កក្កដា ២០២២
បានដាក់ឱ្យដំណើរការគម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទានសម្រាប់វិស័យទេសចរណ៍

### ០១ មករា ២០២៣
ការដាក់ឱ្យដំណើរការ "គម្រោងធានាឥណទានជាកញ្ចប់"

### ២២ សីហា ២០២៣
បានទទួលស្គាល់ពី SERC ជាស្ថាប័នធានាលើការបោះផ្សាយសញ្ញាបណ្ណដំបូងគេបង្អស់នៅកម្ពុជា

## ស្វាគមន៍សមាជិកគ្រួសារថ្មីរបស់បុគ្គលិក CGCC | Welcome CGCC Staff's Baby

KH តាងនាមឱ្យថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ CGCC យើងសូមចូលរួមអបអរសាទរចំពោះ លោកស្រី ណែត ស្រីយក់ថុង បុគ្គលិកជំនាញនៃនាយកដ្ឋានហិរញ្ញវត្ថុ និងវិភាគអាជីវកម្ម ក្នុងឱកាសដ៏វិសេសវិសាលបំផុតក្នុងជីវិត ដែលបានទទួលនូវសមាជិកថ្មី ចូលមកក្នុងគ្រួសាររបស់លោកស្រី។ យក់ថុង ដែលជាបុគ្គលិកដ៏ល្អម្នាក់របស់ CGCC បានសម្រាលកូនស្រីដ៏គួរឱ្យស្រឡាញ់ម្នាក់ កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣។

ក្នុងស្មារតីរួមនៃការអរអបសាទរនេះ CGCC សូមជូនពរដោយស្មោះអស់ពីដួងចិត្ត ជូនដល់ យក់ថុង និងគ្រួសារ ឱ្យជួបប្រទះតែសុខសុភមង្គល វិបុលសុខ និងមានជីវិតពោរពេញដោយក្តីស្រឡាញ់យ៉ាងកក់ក្តៅ៕



EN CGCC's management and staff would like to extend our heartfelt congratulations to Ms. Neth Sreyyuokthong, our Executive Finance and Business Analytics, on the arrival of a beautiful new life into her family. Yuokthong, one of CGCC dedicated staff, safely delivered her baby girl on 30 August 2023.

In the spirit of celebration, we extend our warmest wishes and blessings to Yuokthong and her family. May this new chapter be filled with prosperity, laughter, and warm love.

## ជួបជាមួយបុគ្គលិករបស់ CGCC | Meeting with CGCC's Employee



“ខ្ញុំពិតជាមានសេចក្តីរីករាយ ក្នុងការធ្វើការជិតស្និទ្ធជាមួយមិត្តរួមការងារគ្រប់ៗគ្នា ក្រោមការដឹកនាំរបស់គណៈគ្រប់គ្រងរបស់ CGCC។ ក្នុងការអនុវត្តគម្រោងលទ្ធកម្មនីមួយៗ ក្រុមការងាររបស់នាងខ្ញុំតែងតែគាំទ្រយ៉ាងពេញទំហឹង ព្រមទាំងផ្តល់គំនិត និងអនុសាសន៍ល្អៗ ដែលអាចនាំមកនូវអត្ថប្រយោជន៍ជាវិជ្ជមានដល់ CGCC។”

**លោកស្រី គីម ចាន់ថាវី**
**អនុប្រធានការិយាល័យលទ្ធកម្ម**
**Ms. Kem Chanthavy,**
**Deputy Manager of Procurement**

KH នៅចុងឆ្នាំ២០២១ នាងខ្ញុំបានសម្រេចចិត្តចូលបម្រើការងារនៅ CGCC ជាបុគ្គលិកជាន់ខ្ពស់ផ្នែកលទ្ធកម្ម។ នៅក្នុងខែមេសា ឆ្នាំ២០២៣ នាងខ្ញុំត្រូវបានថ្នាក់ដឹកនាំក្រុមហ៊ុនផ្តល់ការទុកចិត្ត និងតម្លើងតួនាទីជាអនុប្រធានការិយាល័យលទ្ធកម្ម។ ភារកិច្ចសំខាន់របស់នាងខ្ញុំ គឺគាំទ្រនាយកដ្ឋានពាក់ព័ន្ធ ក្នុងការស្វែងរកអ្នកផ្គត់ផ្គង់ ដែលអាចផ្គត់ផ្គង់ផលិតផល និងសេវា ស្របតាមតម្រូវការរបស់ CGCC ប្រកបដោយគុណភាពខ្ពស់ ក្នុងតម្លៃប្រកួតប្រជែង។

“ខ្ញុំពិតជាមានសេចក្តីរីករាយ ក្នុងការធ្វើការជិតស្និទ្ធជាមួយមិត្តរួមការងារគ្រប់ៗគ្នា ក្រោមការដឹកនាំរបស់គណៈគ្រប់គ្រងរបស់ CGCC។ ក្នុងការអនុវត្តគម្រោងលទ្ធកម្មនីមួយៗ ក្រុមការងាររបស់នាងខ្ញុំ តែងតែគាំទ្រយ៉ាងពេញទំហឹង ព្រមទាំងផ្តល់គំនិត និងអនុសាសន៍ល្អៗ ដែលអាចនាំមកនូវអត្ថប្រយោជន៍ជាវិជ្ជមានដល់ CGCC។” ជាងនេះទៅទៀត នាងខ្ញុំបានរៀនសូត្រ និងទទួលបាននូវបទពិសោធន៍ជាច្រើន ក្នុងការអនុវត្តការងារក្នុងវិស័យសាធារណៈ តាមរយៈ CGCC ដែលជាសហគ្រាសសាធារណៈ និងឱកាសធ្វើការដោយផ្ទាល់ជាមួយគណៈគ្រប់គ្រង ដោយអាចរៀនសូត្រពីទស្សនៈរបស់ពួកគាត់ ទាក់ទងនឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដែលអាចជះឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោលដល់ CGCC។

ក្នុងរយៈពេលពីរឆ្នាំមកនេះ នាងខ្ញុំពិតជាពេញចិត្តជាខ្លាំង ក្នុងការធ្វើការនៅ CGCC ពីព្រោះ CGCC បានតែងតែផ្តល់ឱកាស និងលើកទឹកចិត្តឱ្យ នាងខ្ញុំបំពេញការងារដែលនាងខ្ញុំចូលចិត្ត និងដុសខាត់ជំនាញរបស់នាងខ្ញុំជាប្រចាំ។ ជាងនេះទៅ នាងខ្ញុំពិតជាមានមោទនភាព ដែលបានចូលរួមក្នុងបេសកកម្មរបស់ CGCC ដើម្បីបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា សំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ខ្ញុំប្រកបដោយចីរភាព៕

EN At the end of 2021, I decided to join CGCC as a Senior Executive of Procurement. In April 2023, I was promoted to Deputy Manager of Procurement. My main task is to support the relevant departments in finding suppliers who can supply products and services following the CGCC's requirements with high quality at competitive prices.

"I really enjoy working closely with all my colleagues and under the CGCC's management team. In the implementation of each procurement project, the team always provides full supports and good ideas and recommendations that can bring benefits to CGCC." Moreover, I also learned and gained a lot of experience in working in the public sector through CGCC which is a state-owned enterprise, and the opportunity to work directly with the management by learning from their legal perspective and policy frameworks that can directly and indirectly impact CGCC.

For the past two years, I am very happy to work at CGCC as CGCC has always provided opportunities and encourages me to do my favorite job and hone my skills regularly. Furthermore, I am very proud to participate in the mission of CGCC to improve the financial inclusion and promote the development of small and medium enterprises in Cambodia to participate in the socio-economic development of my country.

# វឌ្ឍនភាពការធានាឥណទាន | Credit Guarantee Progress

ដោយ៖ លោកស្រី ពិន ម៉ានីកា ប្រធានការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម | By: Ms. Pin Manika, Manager of Marketing and Business Development

| | | |
|---|---|---|
| គណនីដែលមានការធានា (GA)<br>Guaranteed Account (GA)<br>**1762** | ឥណទានដែលមានការធានា (GL)<br>Guaranteed Loan (GL)<br>**USD 149.04million Equi.** | សន្និធិឥណទានដែលមានការធានា<br>Outstanding Guaranteed Loan<br>**USD 111.19million Equi.** |
| សន្និធិទំហំការធានាឥណទាន<br>Outstanding Guaranteed Amount<br>**USD 80.11million Equi.** | ភាគរយឥណទានមិនដំណើរការ<br>NPL Ratio of Outstanding Guaranteed Amount<br>**4.62%** | ទំហំសំណងដែលបានបញ្ចេញ<br>Claim Payout<br>**USD 31,480** |

## គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមដែលស្នើសុំការធានាឥណទានបានច្រើនជាងគេ (កក្កដា-កញ្ញា ២០២៣)
## PFIs requesting the most credit guarantees (July-September 2023)

ធនាគារ កាណាឌីយ៉ា 加華銀行 CANADIA BANK | ABA BANK NATIONAL BANK OF CANADA GROUP | LOLC លិលអូរិលស៊ី (ខេមបូឌា) ភីអិលស៊ី LOLC (Cambodia) Plc. | ធនាគារ ស្ថាបនា SATHAPANA BANK

ត្រឹមចុងត្រីមាសទី៣ នៃឆ្នាំ២០២៣នេះ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានផ្តល់ការធានាដល់កម្ចីអាជីវកម្មសរុប ១៧៦២កម្ចី ដែលសមមាត្រនឹងទំហំកម្ចីសរុបប្រហែល ១៤៩,០៩លានដុល្លារ ហើយក្នុងនោះ ១៩៤កម្ចី ត្រូវបានផ្តល់ការធានានៅក្នុងឆ្នាំ២០២១ និង ៧៩១កម្ចី ត្រូវបានផ្តល់ការធានានៅក្នុងឆ្នាំ២០២២។ កម្ចីទាំង១៧៦២ នេះ បានទទួលការធានាក្រោមគម្រោងធានាឥណទានចំនួន៥គឺ គម្រោងធានាឥណទានដើម្បីស្តារអាជីវកម្ម (BRGS) គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន (CFGS) គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី (WEGS) គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទានសម្រាប់វិស័យទេសចរណ៍ (CFGS-TR) និងគម្រោងធានាឥណទានជាកញ្ចប់ (PGS)។ ត្រឹមចុងត្រីមាសទី៣ ឆ្នាំ២០២៣ សន្និធិទំហំការធានាឥណទានសរុប គឺមានចំនួន ៨០,១១ លានដុល្លារ ដែលនេះ គឺជាទំហំហានិភ័យសរុបរបស់ CGCC។ ក្នុងនោះ ៤,៦២% គឺជាទំហំការធានាឥណទានមិនដំណើរការ (NPL)។

As of the end of the third quarter 2023, the Credit Guarantee Corporation of Cambodia (CGCC) has provided guarantees for a total of 1,762 business loans, with the total loan size of approximately $149.09 million. Of these, 194 loans were guaranteed in 2021 and 791 loans were guaranteed in 2022. These 1,762 loans were guaranteed under all 5 CGCC's guarantee schemes: the Business Recovery Guarantee Scheme (BRGS), the Co-Financing Guarantee Scheme (CFGS), the Women Entrepreneurs Guarantee Scheme (WEGS), and the Co-Financing Guarantee Scheme for Tourism (CFGS-TR) and Portfolio Guarantee Scheme (PGS). As of the end of September 2023, the total CGCC's risk exposure is $80.11 million, and among that, 4.62% is the non-performing loans (NPL).

### ១. ការធានាឥណទានប្រចាំខែ |Guarantee Progress by Months

រយៈពេល៩ខែ នៃឆ្នាំ២០២៣នេះ CGCC បានផ្តល់ការធានាឥណទានចំនួន ៧៧៧ កម្ចី ក្នុងទំហំ ៥៦,៣៧លានដុល្លារ ដែលក្នុងនោះមាន ១៤៣កម្ចី ឬស្មើនឹង ២,៥ លានដុល្លារ ជាកម្ចីដែលត្រូវបានផ្តល់ការធានាក្រោមគម្រោងធានាឥណទានជាកញ្ចប់ (PGS) ចំនួន៣ ផ្សេងគ្នា។ ក្នុងត្រីមាសទី៣ ២០២៣ យើងសង្កេតឃើញថា ការធានាឥណទានរបស់ CGCC បានធ្លាក់ចុះមកត្រឹម ១៩៦កម្ចី ស្មើនឹង ១៦,២៦លានដុល្លារ ធៀបនឹង ២៩១កម្ចី ស្មើនឹង ១៩,៣៤លានដុល្លារ ក្នុងត្រីមាសទី២។ ការថយចុះនៃការធានាឥណទាននេះបណ្តាលមកពីកត្តាមួយចំនួនដូចជា ការធ្លាក់ចុះនៃការបញ្ចេញកម្ចីរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ការកើនឡើងនៃអត្រាការប្រាក់ និងចំនួនឥណទានមិនដំណើរការ ក៏ដូចជាវិបត្តិសេដ្ឋកិច្ចពិភពលោកផងដែរ។

For the first nine months of 2023, CGCC provided 777 loan guarantees amounting to $ 56.37 million, of which 143 loans ($2.5 million) were secured under 3 different portfolio guarantee schemes. In the third quarter of 2023, we observed that CGCC credit guarantee decreased noticeably to 196 loans, equivalent to $16.24 million from 291 loans, equivalent to $19.34 million in the second quarter. The decline in CGCC's credit guarantees was due to a number of factors, such as the decline in lending by banks and microfinance institutions, the rise of interest rates and the numbers of non-performing loans, as well as the global economic crisis.

## Guarantee Progress by Months (2023)




| | 2021 | | 2022 | | Jan | | Feb | | Mar | | Apr | | May | | June | | July | | August | | September | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA | GL | GA |
| PGS | 21.3mil | 194 | 71.4mil | 791 | 0 | 0 | .6mil | 31 | .5mil | 29 | .2mil | 10 | .2mil | 10 | .5mil | 28 | .3mil | 18 | .3mil | 14 | .05mil | 3 |
| IGS | | | | | 5.5mil | 60 | 6.0mil | 79 | 8.3mil | 91 | 6.6mil | 82 | 6.7mil | 88 | 5.2mil | 73 | 6.5mil | 64 | 5.1mil | 57 | 4.0mil | 40 |

*Exchange Rate: USD1 = KHR4,122 *IGS : Individual Guarantee Scheme *PGS : Portfolio Guarantee Scheme

## ២. ប្រភេទ និងទំហំកម្ចី |Types and Sizes of Guaranteed Loans

កម្ចីមានកាលកំណត់ គឺតែងតែត្រូវបានដាក់ស្នើសុំការធានាច្រើនជាងគេ ដែលក្នុងនោះមាន ១៣៩០កម្ចី ហើយប្រមាណជាង៧៨% នៃកម្ចីដែលមានការធានាសរុប គឺត្រូវបានប្រើប្រាស់ជាទុនបង្វិល ដែលស្មើនឹង ១៣៧៥កម្ចី។ មានតែ ៣៨២កម្ចីប៉ុណ្ណោះ ដែលត្រូវបានយកមកប្រើប្រាស់សម្រាប់ការវិនិយោគ ឬពង្រីកអាជីវកម្ម។ ក្នុងចំណោមកម្ចីអាជីវកម្មទាំង ១៧៦២ ប្រមាណ៩២% ត្រូវបានស្នើសុំដោយ សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) ហើយមានតែ ១៤៥កម្ចីតែប៉ុណ្ណោះ ដែលជាកម្ចីរបស់សហគ្រាសខ្នាតធំ។ នេះសបញ្ជាក់ឱ្យឃើញថា ទុនបង្វិល នៅតែជាតម្រូវការចម្បង និងបន្ទាន់សម្រាប់ម្ចាស់អាជីវកម្ម ជាពិសេសអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម។

ទំហំកម្ចីដែលមានការធានាឥណទានជាង៥៧% មានទំហំតូចជាង ឬស្មើ៥ម៉ឺនដុល្លារ ដែលនេះជាទំហំកម្ចីសមស្របមួយ សម្រាប់អាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ក្នុងការប្រើប្រាស់ជាទុនបង្វិល ទាំងរយៈពេលវែង និងរយៈពេលខ្លី។ លើសពីនោះ ប្រមាណ៦១,៥% នៃកម្ចីដែលមានការធានាទាំងអស់ (១០៨៤កម្ចី) ជាកម្ចីដែលគ្មានទ្រព្យធានា។

Term loans are the most frequently applied type of guaranteed loans (1,390 loans) and more than 78% (1,375 loans) of the total guaranteed loans are for working capital purposes. Only 382 loans are used for investment or business expansion purposes. Among the 1,762 business loans, around 92% were applied by micro, small and medium enterprises (MSMEs) and only 145 were applied by large firms. This proves that working capital is still the main and urgent need for business owners, especially MSMEs.

More than 57% of guaranteed loans are loans that are less than or equal to $50,000, a suitable loan size for micro, small and medium businesses to use as working capital, both long and short terms. In addition, about 61.5% (1084 loans) of all guaranteed loans are unsecured loans.

### Loan Facility




### Loan Purpose




### Loan Size in KHR




### Loan Size in USD









## ៣. ភូមិសាស្ត្ររបស់កម្ចីដែលមានការធានា |Geographical Coverage (IGS)

CGCC នៅតែបន្តជំរុញការអភិវឌ្ឍរបស់MSMEs ទៅដល់ទូទាំងប្រទេស ដោយបានពង្រីកវិសាលភាពនៃការធានាឥណទានរបស់ខ្លួន បានគ្រប់ទាំង២៥ខេត្ត/ក្រុង ហើយក៏បានបន្តបង្កើនការធានាឥណទាន នៅក្នុងខេត្ត នីមួយៗជាបន្តបន្ទាប់។ ក្នុងនោះ រាជធានីភ្នំពេញនៅតែជាភូមិសាស្ត្រ ដែលមានកម្ចីអាជីវកម្មទទួលបានការធានាច្រើនជាងគេ ដោយកើនឡើងពី ៤៦៤កម្ចី ត្រឹមចុងត្រីមាសទី២ ឆ្នាំ២០២៣ មកដល់ ៥២៣កម្ចី នៅចុងត្រីមាសទី៣ ឆ្នាំ២០២៣។ នៅតាមបណ្តាខេត្តផ្សេងទៀត ដូចជាខេត្តបាត់ដំបង ១៦៣កម្ចី ខេត្តសៀមរាប ៨៧កម្ចី ខេត្តព្រៃវែង ៨៤កម្ចី ខេត្តកំពង់ធំ ៧៦កម្ចី និងខេត្តបន្ទាយមានជ័យ ៧៤កម្ចី។ CGCC នឹងបន្តធានាឱ្យបាននូវនិរន្តភាពនេះ ដោយក្នុងឆ្នាំ២០២៣នេះ CGCCបាន និងបន្តធ្វើបេសកកម្មទៅជួបពិភាក្សាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម និងម្ចាស់អាជីវកម្មនៅតាមបណ្តាខេត្តមួយចំនួន នៅក្នុងគ្រប់តំបន់នៃប្រទេសកម្ពុជា។

CGCC continues to promote the development of MSMEs across the country, extending the outreach of its credit guarantee to all 25 provinces/cities, and has continued to increase the number of guaranteed loans in each province. Phnom Penh is still the region with the most guaranteed loans, increasing from 464 loans by the end of the second quarter 2023 to 523 loans by the end of the third quarter 2023. There is also an increase in other provinces such as Battambang 163 loans, Siem Reap 87 loans, Prey Veng 84 loans, Kampong Thom 76 loans and Banteay Mean Chey 74 loans. CGCC will ensure this sustainability as this year CGCC has done and planned to conduct its road show to meet with PFIs and business owners in some provinces across all regions of Cambodia.




*Geography of each GA is based on Business Address

## ៤. សមាសភាពអ្នកខ្ចី | Gender

ក្នុងចំណោម បេសកកម្មនានារបស់ CGCC ការផ្តល់ការធានាឥណទានជូនសហគ្រិនស្ត្រី និងជំរុញសហគ្រិនស្ត្រីឱ្យទទួលបានហិរញ្ញប្បទានផ្លូវការ គឺជាបេសកកម្មចម្បងមួយដែល CGCC ខិតខំប្រឹងប្រែងបំពេញចាប់តាំងពីការបង្កើត CGCC ដំបូង។ លើសពីនេះ CGCC ក៏បានដាក់ឱ្យដំណើរការនូវគម្រោងធានាឥណទានជាកញ្ចប់សម្រាប់សហគ្រិនស្ត្រីផងដែរ ដើម្បីជំរុញការធានាឥណទានទៅកាន់សហគ្រិនស្ត្រីឱ្យកាន់តែមានភាពរហ័ស និងងាយស្រួលជាងមុន។ ជាលទ្ធផល កំណើននៃសមាសភាពអ្នកខ្ចី ដែលជាស្ត្រីម្ចាស់អាជីវកម្ម មានការកើនឡើងជារៀងរាល់ខែ។ គិតមកត្រឹមត្រីមាសទី៣ នៃឆ្នាំ២០២៣នេះ សមាសភាពអ្នកខ្ចី ដែលជាស្ត្រីម្ចាស់អាជីវកម្មមានចំនួនជាង៤២% (៧៤១កម្ចី) នៃចំនួនអ្នកខ្ចីសរុប ដែលតួលេខនេះ បានកើនឡើងពីត្រឹម២៣% ក្នុងឆ្នាំ២០២១ មកដល់៣៥% ត្រឹមចុងឆ្នាំ២០២២។

Providing credit guarantees to women entrepreneurs and encouraging women entrepreneurs to receive formal financing is one of the main missions that CGCC has been striving to fulfill since its inception. In addition, CGCC has just launched a PGS for women entrepreneurs to ensure the efficiency and promptness in providing credit guarantees to women entrepreneurs. As a result, the composition of female business owners keeps increasing monthly since 2021. As of the third quarter of 2023, the percentage of female business owners accounted for nearly 42% (741 loans) of the total number of borrowers, an increase from 23% in 2021 and from 35% by the end of 2022.



## វឌ្ឍនភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ CGCC | CGCC’s Digital Marketing Progress



KH នៅក្នុងត្រីមាសទី៣ នៃឆ្នាំ២០២៣ នេះ បណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ CGCC កាន់តែសកម្ម និងទទួលស្គាល់ដោយសាធារណជនកាន់តែច្រើន។ គេហទំព័ររបស់ CGCC ក៏ទទួលបានការចូលមើលគួរឱ្យកត់សម្គាល់ ដែលបង្កើតឡើងដោយ ខ្លឹមសារជាក់លាក់ និងថ្មីៗជានិច្ចទាក់ទងនឹងវឌ្ឍនភាពនៃការធានាឥណទាន សកម្មភាព និងព្រឹត្តិការណ៍ និងព័ត៌មាន ប្រកបដោយចំណេះដឹងផ្សេងៗទៀតដែលទាក់ទងនឹងការធានាឥណទាន។

EN In this 3rd quarter of 2023, CGCC’s social media channels have been more active and recognized by more audiences. CGCC’s website also receives noticeable visits generated by our genuinely and constantly updated contents regarding the credit guarantee progress, activities and events, and other resourceful information related to credit guarantee.

ប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័ររបស់ CGCC ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ មានវឌ្ឍនភាពដូចខាងក្រោម៖

CGCC’s social media and website’s progress in the 3rd Quarter of 2023:

- 620 New Likes
- 90 New Likes
- 270 New Followers
- 7K New Visitors

# ការស្ទង់មតិរបស់ PFIs សម្រាប់រយៈពេល ៨ខែដំបូង ឆ្នាំ២០២៣ | PFIs Survey First 8 Months of 2023

**ដោយ៖ លោក គី ហុង បុគ្គលិកជំនាញផ្នែកអភិវឌ្ឍផលិតផល | By: Mr. Ky Hong, Executive of Product Development**



KH ចាប់ពីខែមករា ដល់ខែសីហា ឆ្នាំ២០២៣ CGCC បានធ្វើការស្ទង់មតិរបស់ PFIs មួយចំនួនក្នុងអំឡុងពេលបេសកកម្មរបស់ CGCC ទៅតាមបណ្តាខេត្ត-ក្រុង (Roadshows) ចំនួន ១០ ដើម្បីវាស់ស្ទង់អំពីការយល់ឃើញរបស់ PFIs អំពីគម្រោងធានាឥណទានរបស់ CGCC។ ជាសរុប បុគ្គលិករបស់ PFIs ចំនួន ៤១៨ នៅតាមបណ្តាសាខាខេត្ត-ក្រុងបានចូលរួមក្នុងការស្ទង់មតិនេះ រួមមាន ធនាគារ ABA, ធនាគារ ស្ថាបនា, ធនាគារ អេស៊ីលីដា, ធនាគារ កាណាឌីយ៉ា, ធនាគារ ព្រីនស៍, ធនាគារ មេយប៊ែង, ធនាគារ CIMB, ធនាគារ RHB, ធនាគារ ហ្វីលីព, ធនាគារ FTB, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចម្រើន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC។ ខាងក្រោមនេះ គឺជាលទ្ធផលសំខាន់ៗនៃការស្ទង់មតិនេះ៖

*តើការធានាឥណទានរបស់ CGCC មានអត្ថប្រយោជន៍ដូចម្តេចខ្លះ ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម?*

*What are the benefits of CGCC credit guarantee schemes for PFIs?.*




EN From January to August 2023, CGCC conducted opinion surveys with selected PFIs during the road shows in 10 provinces to gauge the PFI's understanding and perception toward CGCC's credit guarantee schemes. In total, 418 provincial staff from ABA Bank, Sathapana Bank, ACLEDA Bank, Canadia Bank, Prince Bank, Maybank, CIMB Bank, RHB Bank, Philip Bank, FTB Bank, AMK, Chamroeun and LOLC completed the survey. Below are the highlighted results of the survey:

*តើការធានាឥណទានរបស់ CGCC មានអត្ថប្រយោជន៍ដូចម្តេចខ្លះ ចំពោះសហគ្រាសធុនតូច និងមធ្យម (SMEs)?*

*What are the benefits of CGCC credit guarantee schemes for SMEs?*



# កិច្ចសហប្រតិបត្តិការ និងសកម្មភាពនានា | Cooperation and Activities

## កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ | Cooperation and Partnership

### ការចុះកិច្ចព្រមព្រៀងលើគម្រោងធានាឥណទានជាកញ្ចប់ ទំហំ ៣ លានដុល្លារ សម្រាប់សហគ្រិនស្ត្រី

### Signing of a $3 million Portfolio Guarantee Agreement for Women Entrepreneurs Between CGCC and Prince Bank



នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ នៅអគារព្រីនស៍ថៅវើ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងធនាគារព្រីនស៍ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងធានាឥណទានជាកញ្ចប់ ដែលមានទំហំ ៣លានដុល្លារ សម្រាប់សហគ្រិនស្ត្រី។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយ លោក Wong Keet Loong អគ្គនាយក CGCC និង លោក ហ៊ាន់ សុរចនា ប្រធាននាយកប្រតិបត្តិនៃធនាគារ ព្រីនស៍ និងក្រោមវត្តមានកិត្តិយសពី លោកជំទាវ ឧកញ៉ា កែវ មុំ ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា។ គម្រោងធានាឥណទានជាកញ្ចប់ សម្រាប់សហគ្រិនស្ត្រីរបស់ CGCC និងធនាគារព្រីនស៍ នេះគ្រោងនឹងដាក់ឱ្យដំណើរការជាផ្លូវការ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ តទៅ ដែលនឹងអនុញ្ញាតឱ្យធនាគារព្រីនស៍ អាចបញ្ចេញកម្ចីដែលមានការធានា ជូនទៅសហគ្រិនស្ត្រី ដោយមិនចាំបាច់ស្នើសុំការធានាម្តងមួយៗពី CGCC មុនពេលបញ្ចេញកម្ចីទាំងនោះ។ គម្រោងធានាឥណទានជាកញ្ចប់ សម្រាប់សហគ្រិនស្ត្រីនេះ នឹងគាំទ្រដល់ការបញ្ចេញកម្ចីដែលមានការធានាពី CGCC តាមរយៈធនាគារព្រីនស៍ ជូនដល់សហគ្រិនស្ត្រី ដែលខ្វះទ្រព្យធានា ឱ្យកាន់តែបានច្រើន ងាយស្រួល និងរហ័សជាងមុន៕



Read more in English: https://www.cgcc.com.kh/en/article/12324/

### ការចុះអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីបង្កើនលទ្ធភាពទទួលបានកម្ចី ដែលមានការធានាសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម រវាង សាជីវកម្មធានាឥណទានកម្ពុជា សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា និង ធនាគារវីង

### Signing MOU on Strategic Partnership to Support Small and Medium Enterprises in Access to Guaranteed Loans Between CGCC, FASMEC, and Wing Bank






នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) និងធនាគារវីង បានចុះអនុស្សរណៈនៃការយោគយល់គ្នា លើភាពជាដៃគូយុទ្ធសាស្ត្រ ក្នុងគោលបំណងបង្កើនលទ្ធភាពទទួលបានកម្ចីដែលមានការធានា សម្រាប់ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម (SMEs) នៅកម្ពុជា។ កិច្ចសហប្រតិបត្តិការនេះ នឹងផ្តល់ការគាំទ្រដល់សមាជិកសមាជិកា FASMEC ក្នុងការទទួលហិរញ្ញប្បទានចាំបាច់ ឆ្លើយតបទៅនឹងបញ្ហាខ្វះទ្រព្យធានា តាមរយៈការធានាឥណទាន និងជាពិសេសចូលរួមលើកស្ទួយចំណេះដឹងហិរញ្ញវត្ថុ ជូនដល់សមាជិកសមាជិការបស់ FASMEC នៅទូទាំងប្រទេស៕

Read more in English: https://www.cgcc.com.kh/en/article/12752/

## វគ្គបណ្តុះបណ្តាលអំពីប្រព័ន្ធ GMS ទៅកាន់គ្រឹស្ថានហិរញ្ញវត្ថុចូលរួម

## Training on Guarantee Management System (GMS) to PFIs



នាយកដ្ឋានប្រតិបត្តិការរបស់ CGCC បានផ្តល់វគ្គបណ្តុះបណ្តាលចែករំលែកអំពីប្រព័ន្ធ GMS ក្នុងរយៈពេល ៧សប្តាហ៍ ដែលចាប់ផ្តើមពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ នៅការិយាល័យ CGCC ទៅកាន់ PFIs ចំនួន ២១ស្ថាប័ន ដោយមានអ្នកចូលរួមសរុបចំនួន ៨០នាក់។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងបណ្តុះបណ្តាលបុគ្គលិកស្នូលរបស់ PFIs អំពីការប្រើប្រាស់ប្រព័ន្ធ GMS ក្នុងការស្នើសុំការធានាឥណទានពី CGCC៕

Read more in English: https://www.cgcc.com.kh/en/article/12637/

## កិច្ចពិភាក្សាស្វែងយល់ និងពង្រឹងកិច្ចសហការលើការធានាឥណទាន រវាង CGCC និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម សាខាខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន

## CGCC’s visits to PFIs provincial branches in Kampong Chnang, Pursat, Battambang & Pailin to Enhance Collaboration on the Credit Guarantee

កាលពីថ្ងៃទី១១ ខែកញ្ញា ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដឹកនាំដោយ លោក ហោ សៅរ៍ពិសិដ្ឋ ប្រធានការិយាល័យប្រតិបត្តិការ បានជួបពិភាក្សាស្វែងយល់អំពីការអនុវត្តគម្រោងធានាឥណទាន និងផ្សព្វផ្សាយបន្ថែមអំពីគម្រោងធានាឥណទានរបស់ CGCC ដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំ និងបុគ្គលិករបស់សាខានៃ PFIs មួយចំនួនរបស់ CGCC រួមមាន៖

- នៅខេត្តកំពង់ឆ្នាំង រួមមាន ធនាគារ ABA និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន
- ខេត្តពោធិ៍សាត់ រួមមាន ធនាគារព្រីនស៍ ធនាគារកាណាឌីយ៉ា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន
- នៅខេត្តបាត់ដំបង រួមមាន ធនាគារព្រីនស៍ ធនាគារ FTB និងធនាគារ Maybank
- នៅខេត្តប៉ៃលិន រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC ធនាគារហ្វីលីព និងធនាគារ ABA

កិច្ចពិភាក្សាជាមួយ PFIs របស់ CGCC នៅខេត្តទាំងបួន ដែលជាខេត្តមានសក្តានុពលនៃអាជីវកម្មរបស់សហគ្រាសខ្នាតតូចនិងមធ្យម គឺជាឱកាសមួយដ៏ពិសេសសម្រាប់ទាំង CGCC និង PFIs ស្វែងយល់អំពីភាពចាំបាច់នៃការធានាឥណទាន និងឱកាសដែល PFIs អាចបង្កើនការផ្តល់កម្ចីជូនទៅដល់ក្រុមហ៊ុនអាជីវកម្ម ដែលមានតម្រូវការកម្ចីតែខ្វះទ្រព្យធានា៕












Read more in English: https://www.cgcc.com.kh/en/article/12887/

# ការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីការធានាឥណទាន | Raising Awareness of Credit Guarantee

## សិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី “កម្ចីដែលមានការធានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម” នៅខេត្តប៉ៃលិន

## Dissemination Seminar on “Guaranteed Loans to Support the Development of Small and Medium Enterprises” in Pailin Province

នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និង សភាពាណិជ្ជកម្មកម្ពុជា (CCC) បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី “កម្ចីដែលមានការធានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម” នៅខេត្តប៉ៃលិន ក្រោមកិច្ចសហការចូលរួមដោយ សភាពាណិជ្ជកម្មខេត្តប៉ៃលិន ដែលក្នុងនោះមានសមាសភាពចូលរួមពី សំណាក់ថ្នាក់ដឹកនាំ និងបុគ្គលិកនៃគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) មួយចំនួន និងបណ្ដាសហគ្រិនដែលជាម្ចាស់អាជីវកម្មខ្នាតតូច និងមធ្យម នៅក្នុងខេត្តប៉ៃលិន និងបណ្ដាខេត្តផ្សេងៗទៀតជាង ៨០នាក់។ សិក្ខាសាលាផ្សព្វផ្សាយនេះ ទទួលបានការអញ្ជើញចូលរួមជាអធិបតីដោយ លោកឧកញ៉ា ឡោ ស៊ុនជាង ប្រធានសភាពាណិជ្ជកម្មខេត្តប៉ៃលិន លោក ណូ លីដា អគ្គនាយករង CGCC លោក ហ៊ុន វត្ថា អនុប្រធានក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ព្រមទាំងការធ្វើបទបង្ហាញរបស់អ្នកតំណាងមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC និងធនាគារ ABA ផងដែរ។

តាមរយៈសិក្ខាសាលាផ្សព្វផ្សាយនេះ សហគ្រិននៃអាជីវកម្មខ្នាតតូច និងមធ្យម បានជ្រាបអំពីព័ត៌មាននៃអត្ថប្រយោជន៍ពីកម្ចីដែលមានការធានាតាមរយៈ PFIs របស់ CGCC ឆ្លើយតបទៅនឹងបញ្ហាខ្វះទ្រព្យធានាពេលស្នើសុំកម្ចី សម្រាប់ពង្រីក និងស្ដារអាជីវកម្មរបស់ខ្លួនទៀតផង៕

Read more in English: https://www.cgcc.com.kh/en/article/12898/








# កិច្ចប្រជុំសំខាន់ៗ | Notable Meetings

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល CGCC អាណត្តិទី១ លើកទី១៥

## 15th Board of Directors Meeting of Credit Guarantee Corporation of Cambodia (CGCC)



នៅថ្ងៃទី៧ និងថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ២: 00នាទីរសៀល CGCC បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាណត្តិទី១ លើកទី១៥ នៅការិយាល័យកណ្តាលរបស់ CGCC ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ CGCC ដោយមានការចូលរួមពី សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ។

របៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥ នេះ រួមមាន៖

១ | របាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់ CGCC

២ | ផែនការអាជីវកម្ម និងផែនការថវិការប្រចាំឆ្នាំ២០២៤

៣ | គម្រោងហិរញ្ញប្បទាន SDG ជាមួយ UNDP

៤ | ផ្សេងៗ៕

Read more in English: https://www.cgcc.com.kh/en/article/13092/





# សកម្មភាពផ្សេងៗ | Other Activities

## កិច្ចប្រជុំបុគ្គលិកលើកទី២ ប្រចាំឆ្នាំ២០២៣ “ស្តីអំពីវឌ្ឍនភាពប្រចាំត្រីមាសទី២ ២០២៣ និងផែនការការងារសម្រាប់ត្រីមាសទី៣”

### 2nd Town Hall Meeting on Q2 Progress and Q3 Plan



ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ CGCC បានរៀបចំនូវកិច្ចប្រជុំបុគ្គលិកលើក ទី២ ប្រចាំឆ្នាំ២០២៣ ដើម្បីធ្វើរបាយការណ៍វឌ្ឍនភាពជូនគណៈកម្មាធិការប្រតិបត្តិរបស់ CGCC និងចែករំលែកជូនបុគ្គលិកទាំងអស់ អំពីវឌ្ឍនភាពការងាប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ និងជាពិសេស ទៅលើផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានមួយចំនួន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៣។ កិច្ចប្រជុំបុគ្គលិក CGCC លើកទី២ ប្រចាំឆ្នាំ២០២៣ **“ស្តីអំពីវឌ្ឍនភាពប្រចាំត្រីមាសទី២ ២០២៣ និងផែនការការងារសម្រាប់ត្រីមាសទី៣ ២០២៣”** មានការចូលរួមពីគ្រប់បុគ្គលិកទាំងអស់របស់ CGCC និងមានការចូលរួមជាភ្ញៀវកិត្តិយស និងការផ្តល់បទបង្ហាញពីសំណាក់លោក លន់ សំអុល ប្រធាននាយកដ្ឋានត្រួតពិនិត្យ១ នៃធនាគារជាតិនៃកម្ពុជា។ កិច្ចប្រជុំនេះ មិនមែនត្រឹមតែជាវេទិកាដើម្បីធ្វើបទបង្ហាញពីនាយកដ្ឋានពាក់ព័ន្ធទាំងអស់នោះទេ តែជាឱកាសក្នុងការជួបពិភាក្សា ក៏ដូចជាទទួលនូវអនុសាសន៍ ស្របជាមួយទិសដៅដើម្បីអភិវឌ្ឍ CGCC លើប្រតិបត្តិការការងារ និងចូលរួមចំណែកសម្រេចចក្ខុវិស័យរួមរបស់ CGCC ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា៕



Read more in English: https://www.cgcc.com.kh/en/article/12336/

## កម្មវិធីបរិច្ចាគឈាមជាមួយ មជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច និមជ្ឈមណ្ឌលជាតិផ្តល់ឈាម

### Blood Donation with Business Development Center & the National Blood Transfusion Center




នាព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ បុគ្គលិក CGCC បានចូលរួមចំណែកជាមួយមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច និងមជ្ឈមណ្ឌលជាតិផ្តល់ឈាម នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ក្នុងការបរិច្ចាគឈាមដើម្បីចូលរួមជួយសង្គ្រោះជីវិតអ្នកជំងឺដែលកំពុងខ្វះខាត និងត្រូវការឈាមជាចាំបាច់៕

Read more in English: https://www.cgcc.com.kh/en/article/12621/

## ដំណើរទស្សនកិច្ចសិក្សារបស់ CGCC ទៅកាន់សារមន្ទីរព្រះស្រីឦសានវរ្ម័ន

### CGCC Visited the Preah Srey Içanavarman Museum – Sosoro



កាលពីរសៀល ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ថ្នាក់ដឹកនាំ និងបុគ្គលិក CGCC ទាំងអស់បានធ្វើទស្សនកិច្ចសិក្សាទៅកាន់សារមន្ទីរ ព្រះស្រីឦសានវរ្ម័ន។ ក្នុងដំណើរទស្សនកិច្ចសិក្សានេះ បុគ្គលិក CGCC ទាំងអស់បានស្វែងយល់អំពីប្រវត្តិរូបិយវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានអាយុកាលជាង ២០០០ឆ្នាំ ចាប់តាំងពីសម័យហ្វូណន រហូតដល់សម័យបច្ចុប្បន្ន និងតួនាទីរបស់រូបិយវត្ថុក្នុងការរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ៕

Read more in English: https://www.cgcc.com.kh/en/article/12709/

## កម្មវិធីបណ្ដុះបណ្ដាលប្រចាំឆ្នាំ លើកទី៣១ របស់ ACSIC នៅប្រទេសឥណ្ឌូនេស៊ី

### 31st Asian Credit Supplementation Institution Confederation (ACSIC) in Indonesia

លោក ណូ លីដា អគ្គនាយករង CGCC បានដឹកនាំក្រុមការងារ CGCC ចូលរួមកម្មវិធីបណ្ដុះបណ្ដាលប្រចាំឆ្នាំ លើកទី៣១ របស់ ACSIC នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដែលត្រូវបានរៀបចំឡើងដោយសមាគមសាជីវកម្មធានាឥណទានប្រទេសឥណ្ឌូនេស៊ី – Indonesia Guarantee Corporation Association (ASIPPINDO) ហើយក៏បានចូលរួមជាវាគ្មិនកិត្តិយស ក្នុងការចែករំលែកអំពីគម្រោងធានាឥណទានរបស់ប្រទេសកម្ពុជា ក្រោមប្រធានបទរួមគឺ “Building a Resilient Future: Enabling Sustainable Credit Supplementation”។

កម្មវិធីបណ្ដុះបណ្ដាលនេះ មានការចូលរួមពីតំណាងសមាជិក និងអ្នកសង្កេតការណ៍របស់ ACSIC ជាង៦០រូប មកពី ១២ប្រទេសនៅក្នុងទ្វីបអាស៊ី រួមមានប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឥណ្ឌា ជប៉ុន កូរ៉េ ម៉ាឡេស៊ី ម៉ុងហ្គោលី នេប៉ាល់ ប៉ាពួអាស៊ីនូវែលហ្គីណេ ហ្វីលីពីន តៃវ៉ាន់ និងប្រទេសថៃ៕







Read more in English: https://www.cgcc.com.kh/en/article/12516/

## សន្និសីទប្រចាំឆ្នាំ លើកទី៣៥ របស់ ACSIC នៅប្រទេសម៉ុងហ្គោលី

### 35th Asian Credit Supplementation Institution Confederation (ACSIC) Conference in Mongolia



នាថ្ងៃទី៧ ដល់ទី១១ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល CGCC បានដឹកនាំគណៈប្រតិភូពី CGCC ចូលរួមសន្និសីទប្រចាំឆ្នាំលើកទី៣៥ របស់ ACSIC នៅទីក្រុង Ulaanbaatar ប្រទេសម៉ុងហ្គោលី ដែលត្រូវបានរៀបចំឡើងដោយមូលនិធិ Edit Caption ធានាឥណទានប្រទេសម៉ុងហ្គោលីក្រោមប្រធានបទ “Looking ahead: fostering green financing for sustainable development”។




នៅក្នុងសន្និសីទនេះ ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានអញ្ជើញផ្ដល់ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ ដើម្បីថ្លែងសុន្ទរកថាស្វាគមន៍ ទៅកាន់បណ្ដាប្រតិភូពីស្ថាប័នធានាឥណទាននានា អំពីយន្តការធានាឥណទានរបស់កម្ពុជា ដែលដើរតួនាទីយ៉ាងសំខាន់ចូលរួមចំណែកដល់និរន្តរភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ តាមរយៈសន្និសីទនេះ ប្រតិភូតំណាងស្ថាប័នចូលរួមមានឱកាសក្នុងការចែករំលែក និងផ្លាស់ប្ដូរទស្សនៈលើប្រធានបទនានាជុំវិញហិរញ្ញប្បទានបៃតង សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមរយៈរបៀបវារៈដែលមានដូចជាកិច្ចពិភាក្សា កិច្ចសន្ទនាពីអ្នកជំនាញ និងសុន្ទរកថាគន្លឹះនានា ដែលនាំមកនូវកិច្ចខិតខំប្រឹងប្រែងជារួម ឆ្ពោះទៅរកការកសាង និងអភិវឌ្ឍហិរញ្ញប្បទានបៃតង ដែលជាកត្តាជំរុញដ៏សំខាន់ នៃការអភិវឌ្ឍជាវិជ្ជមាន។ ប្រធានបទនៃសន្និសីទរបស់ ACSIC លើកទី៣៥ នេះ មិនត្រឹមតែពាក់ព័ន្ធសម្រាប់ស្ថាប័នចូលរួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសារៈសំខាន់ក្នុងដោះស្រាយនឹងបញ្ហាប្រឈម ផ្នែកបរិស្ថាននាពេលបច្ចុប្បន្នផងដែរ៕

Read more in English: https://www.cgcc.com.kh/en/article/12672/

## វគ្គបណ្តុះបណ្តាល ស្តីពី “PowerPoint Designs and Presentation Skills”

### Training on “PowerPoint Designs and Presentation Skills”



កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ CGCC បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី “PowerPoint Designs and Presentation Skills” ជូនដល់បុគ្គលិកទាំងអស់ នៅការិយាល័យកណ្តាលរបស់ CGCC។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងជួយបង្កើនសមត្ថភាព និងចំណេះដឹងបន្ថែមអំពីវិធីសាស្ត្រនៃការរៀបចំបទបង្ហាញ និងជំនាញនៃការធ្វើបទបង្ហាញ ជូនដល់បុគ្គលិក ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់ពួកគេ ក៏ដូចជាការអភិវឌ្ឍ CGCC ទាំងមូល៕





Read more in English: https://www.cgcc.com.kh/en/article/12946/

## ការកោតសរសើរនិងទទួលស្គាល់ ចំពោះការច្នៃប្រឌិតផលិតផលប្រចាំឆ្នាំ

### Product Innovation of the Year

CGCC មានកិត្តិយសក្នុងការទទួលបានការកោតសរសើរនិងទទួលស្គាល់ ចំពោះការច្នៃប្រឌិតផលិតផលប្រចាំឆ្នាំ (Product Innovation of the Year) ក្នុងកម្មវិធី Global SME Finance Awards 2023។ កម្មវិធី Global SME Finance Awards 2023 ធ្វើការទទួលស្គាល់ស្ថាប័នហិរញ្ញវត្ថុ និងក្រុមហ៊ុន fintech នានាសម្រាប់សមិទ្ធផលឆ្នើមរបស់ពួកគេក្នុងការចែកចាយផលិតផល និងសេវាកម្មពិសេសរបស់ពួកគេដល់អតិថិជន សំដៅលើសហគ្រាសខ្នាតតូច និងមធ្យម (SME)។ កម្មវិធី Global SME Finance Awards បានផ្តល់ឱកាសសម្រាប់ស្ថាប័ននានាដើម្បីបង្ហាញ និងចែករំលែកការអនុវត្ត និងចំណេះដឹងល្អៗតាមរយៈការរៀបចំដោយ SME Finance Forum និងគាំទ្រដោយ G20’s Global Partnership for Financial Inclusion (GPFI)៕



## អត្ថបទស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងការធានា (GMS) | Understanding GMS of CGCC

### ស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងការធានាឥណទានរបស់ CGCC

**ដោយ៖ លោក មួង សុខប៊ូ ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា**

KH អាជីវកម្មមួយ មិនអាចរីកចម្រើនអស់លទ្ធភាពនោះទេ ប្រសិនមិនប្រើប្រាស់បច្ចេកវិទ្យា។ អាជីវកម្មរបស់ CGCC ក៏ដូច្នេះដែរ។ លោក ប៊ីល ហ្គេត ស្ថាបនិករបស់ក្រុមហ៊ុន Microsoft បានលើកឡើងថា៖ ***"បច្ចេកវិទ្យាព័ត៌មាន និងអាជីវកម្មបានភ្ជាប់គ្នាដ៏ស្អិតរមួត។ ខ្ញុំយល់ថា យើងមិនអាចនិយាយដោយមានន័យអំពីអាជីវកម្ម ដោយមិននិយាយអំពីបច្ចេកវិទ្យាព័ត៌មាននោះទេ។"*** ចាប់តាំងពីថ្ងៃដំបូងនៃអាជីវកម្ម CGCC បានប្រកាន់ភ្ជាប់នូវការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយចាប់ផ្ដើមពីការប្រើប្រាស់កម្មវិធីអ៊ិចសែល និងកម្មវិធី Microsoft SharePoint ដើម្បីគ្រប់គ្រងប្រតិបត្តិការធានាឥណទាន។ ថ្ងៃនេះ CGCC បានសម្រេចលទ្ធផលថ្មីមួយទៀត គឺការដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការធានាឥណទាន (GMS) ដើម្បីបង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងប្រតិបត្តិការធានាឥណទាន ប្រកបដោយប្រសិទ្ធភាព។ ការចាប់យកបច្ចេកវិទ្យាព័ត៌មាន គឺជាការប្ដេជ្ញាចិត្តរបស់ CGCC ក្នុងការចូលរួមមួយចំណែកតូច ក្នុងការគាំទ្រអាទិភាពគន្លឹះទាំងប្រាំ (មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា) នៃ "យុទ្ធសាស្ត្របញ្ចកោណ៖ ដំណាក់កាលទីមួយ" របស់រាជរដ្ឋាភិបាលកម្ពុជា។

### *តើ GMS ជាអ្វី?*

GMS គឺជាប្រព័ន្ធឌីជីថល ដែលធ្វើស្វ័យប្រវត្តិកម្ម និងសម្រួលដំណើរការ នៃការធានាឥណទាន ឱ្យមានលក្ខណៈងាយស្រួល លឿន និងមានសុវត្ថិភាព។ GMS គឺជាប្រព័ន្ធឌីជីថលគ្រប់គ្រងប្រតិបត្តិការធានាឥណទានដំបូងគេបង្អស់ និងមានតែមួយគត់នៅកម្ពុជា ដែលត្រូវបានបង្កើតឡើងជាក់លាក់ សម្រាប់តែម៉ូដែលនៃការធានាឥណទានរបស់ CGCC។ វាគឺជាប្រព័ន្ធ ដែលផ្អែកលើបណ្ដាញអ៊ីនធឺណែត និងត្រូវបានបង្កើតឡើងដោយប្រើប្រាស់ស្ថាបត្យកម្មសេវាកម្មលក្ខណៈមីក្រូ និងបច្ចេកវិទ្យាទំនើប ដើម្បីបង្កើនប្រសិទ្ធភាព ភាពត្រឹមត្រូវ និងសុវត្ថិភាពនៃដំណើរការធានាឥណទាន។

### *តើ GMS ត្រូវបានបង្កើតឡើងយ៉ាងដូចម្ដេច?*

CGCC បានអភិវឌ្ឍ GMS ជាដំណាក់កាល។ GMS ដំណាក់កាលទី១ ត្រូវបានចំណាយពេលក្នុងការអភិវឌ្ឍអស់រយៈពេលប្រមាណ២ឆ្នាំ ដោយក្រុមអ្នកជំនាញអភិវឌ្ឍន៍កម្មវិធីដែលមានបទពិសោធន៍ខ្ពស់។ ការអភិវឌ្ឍ GMS ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រ ដែលមានលក្ខណៈបត់បែនឆាប់រហ័ស (Agile Approach) ដោយត្រូវបានកែលម្អជាប្រចាំ ផ្អែកលើមតិយោបល់ពីអ្នកប្រើប្រាស់ផ្ទាល់។ GMS ត្រូវបានអភិឌ្ឍ ដោយភាពប្រុងប្រយ័ត្នខ្ពស់ និងត្រូវបានធ្វើតេស្តដោយយកចិត្តទុកដាក់ និងម៉ត់ចត់ មុននឹងដាក់ឱ្យដំណើរការ ដើម្បីធានាសុវត្ថិភាព និងភាពជឿទុកចិត្តបាន។ នៅក្នុងដំណាក់កាលទីមួយ GMS ផ្ដល់លក្ខណៈសំខាន់ៗ ដូចខាងក្រោម៖

- ***ស្វ័យប្រវត្តិកម្មទាំងស្រុង៖*** GMS ធ្វើស្វ័យប្រវត្តិកម្មដំណើរការការធានាឥណទានទាំងមូល ចាប់ពីការស្នើសុំការធានាពី PFIs រហូតដល់ការអនុម័តការធានាឥណទានរបស់ CGCC។ ការផ្ដល់ និងកែតម្រូវព័ត៌មានដោយស្វ័យប្រវត្តិ ត្រូវបានដាក់បញ្ចូលក្នុង GMS ដើម្បីកាត់បន្ថយកំហុស និងពេលវេលា ក្នុងការបង្កើតសំណើសុំការធានាឥណទាន និងការវាយតម្លៃសំណើធានាឥណទានផងដែរ។
- ***ការតាមដានដោយផ្ទាល់គ្រប់ពេលវេលា៖*** GMS ផ្ដល់មធ្យោបាយសម្រាប់ការតាមដានដោយផ្ទាល់គ្រប់ពេលវេលាអំពីវឌ្ឍនភាពនៃសំណើសុំការធានាឥណទាន ដោយអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចឆែកមើលបច្ចុប្បន្នភាពនៃការវាយតម្លៃសំណើសុំការធានាឥណទានពី CGCC បានគ្រប់ពេលវេលា។
- ***របាយការណ៍យ៉ាងទូលំទូលាយ៖*** GMS បង្កើតរបាយការណ៍ដោយស្វ័យប្រវត្តិយ៉ាងទូលំទូលាយ អំពីការធានាឥណទាន សម្រាប់ការវិភាគទិន្នន័យអំពីការធានាឥណទាន ដើម្បីធ្វើការកែតម្រូវ និងការសម្រេចចិត្ត។
- ***សុវត្ថិភាពខ្ពស់៖*** GMS ត្រូវបានរៀបចំនៅលើប្រព័ន្ធសុវត្ថិភាព និងប្រើប្រាស់បច្ចេកវិទ្យាសុវត្ថិភាពចុងក្រោយបំផុតដើម្បីការពារទិន្នន័យរបស់អ្នកប្រើប្រាស់។



## *អត្ថប្រយោជន៍របស់ GMS*

ការបង្កើនផលិតភាព គឺជាគោលការណ៍ស្នូលមួយរបស់ CGCC ក្នុងការអភិវឌ្ឍ GMS។ CGCC រំពឹងថា GMS នឹងបង្កើនផលិតភាពការធានាឥណទាន តាមរយៈការផ្តល់អត្ថប្រយោជន៍ដល់ PFIs និង CGCC ដូចខាងក្រោម៖

### PFIs

- *ភាពងាយក្នុងការប្រើប្រាស់៖* GMS អនុញ្ញាតឱ្យ PFIs ប្រើប្រាស់ផលិតផលធានាឥណទានរបស់ CGCC បានយ៉ាងងាយស្រួល តាមរយៈប្រព័ន្ធកណ្តាលតែមួយ ដែលអាចស្នើ និងតាមដានសំណើធានាឥណទាន។
- *ការកាត់បន្ថយបន្ទុកការងារ៖* GMS ធ្វើស្វ័យប្រវត្តិកម្មនៃកិច្ចការជាច្រើនពាក់ព័ន្ធ ដំណើរការធានាឥណទាន ដូចជាការទូទាត់មុនកាលកំណត់ការលុបចោល និងការធ្វើវិសោធនកម្មលើកម្ចីដែលមានការធានាព្រមទាំងការផ្ញើរបាយការណ៍ប្រចាំខែ អំពីកម្ចីដែលមានការធានាមកកាន់CGCC ជាដើម។
- *បង្កើនល្បឿនដំណើរការ៖* GMS កាត់បន្ថយពេលវេលាយ៉ាងច្រើនក្នុងដំណើរការវាយតម្លៃសំណើសុំការធានាឥណទាន។ មានន័យថា PFIs អាចបញ្ចេញកម្ចីដែលមានការធានាបានលឿនជាងមុន។
- *កាត់បន្ថយហានិភ័យនៃការក្លែងបន្លំ៖* GMS រួមបញ្ចូលនូវមុខងារមួយចំនួន ដើម្បីជួយកាត់បន្ថយហានិភ័យនៃការក្លែងបន្លំ ដូចជាការផ្ទៀងផ្ទាត់អ្នកប្រើប្រាស់ និងការអ៊ិនគ្រីបទិន្នន័យ ជាដើម។

### CGCC

- *ការបង្កើនប្រសិទ្ធភាព៖* បង្កើនប្រសិទ្ធភាព និងកាត់បន្ថយពេលវេលាក្នុងការអនុម័តសំណើធានាឥណទាន តាមរយៈការធ្វើស្វ័យប្រវត្តិកម្មនៃលំហូរការធានាឥណទាន។
- *ការបង្កើនភាពត្រឹមត្រូវ៖* តាមរយៈការកាត់បន្ថយការបញ្ចូលទិន្នន័យដោយដៃ និងការកែតម្រូវដោយស្វ័យប្រវត្តិ GMS ធានាភាពត្រឹមត្រូវ និងភាពជឿទុកចិត្តបាន។
- *ការបង្កភាពងាយស្រួលនៃទំនាក់ទំនង៖* GMS ជួយសម្រួលដល់ការប្រាស្រ័យទាក់ទងគ្នាយ៉ាងរលូនរវាង CGCC និង PFIs ដើម្បីចែករំលែកព័ត៌មាន និងដោះស្រាយបញ្ហា ប្រកបដោយប្រសិទ្ធភាព។
- *ការបង្កើនបទពិសោធន៍ល្អរបស់អតិថិជន៖* GMS ធ្វើឱ្យ PFIs កាន់តែងាយស្រួល ក្នុងការប្រើប្រាស់ផលិតផល និងសេវាកម្មធានាឥណទានរបស់ CGCC។

## *ផែនការបន្ទាប់*

GMS ត្រូវបានអភិវឌ្ឍ ដោយទុកលទ្ធភាពឱ្យ GMS ពង្រីកវិសាលភាព និងបន្ថែមតួនាទីនាពេលអនាគត។ CGCC ប្តេជ្ញាបន្តអភិវឌ្ឍ GMS ឱ្យស្របនឹងការវិវឌ្ឍនៃអាជីវកម្មរបស់ CGCC។ នៅក្នុងរយៈពេលខ្លីខាងមុខ GMS នឹងគ្របដណ្តប់ដំណើរការទាំងមូលពីដើមដល់ចប់ នៃគម្រោងធានាឥណទានឯកត្តឥណទាន និងគម្រោងធានាឥណទានជាកញ្ចប់។ លើសពីនេះ CGCC នឹងសិក្សាអំពីលទ្ធភាពក្នុងការតភ្ជាប់ GMS ជាមួយនឹងប្រព័ន្ធផ្សេងទៀត ដូចជាប្រព័ន្ធធនាគាររបស់ PFIs ដើម្បីឱ្យកាន់តែមានភាពងាយស្រួលសម្រាប់ PFIs ក្នុងការស្នើសុំការធានាឥណទានពី CGCC និងការតភ្ជាប់ GMS ជាមួយនឹងប្រព័ន្ធរបស់ CBC ដើម្បីបង្កើនប្រសិទ្ធភាពនៃការតាមដានកម្ចីដែលមានការធានា និងរបាយការណ៍ឥណទាន។

ពិតណាស់ CGCC មិនរំពឹងថា GMS នឹងដំណើរការទៅដោយរលូនទាំងស្រុងដោយមិនមានភាពរអាក់រអួលនោះទេ ជាពិសេស នៅក្នុងដំណាក់កាលដំបូង។ កំហុស បញ្ហា និងភាពរាំងស្ទះមួយចំនួន អាចនឹងកើតមានឡើង ដែលទាមទារនូវដំណោះស្រាយជាប្រចាំ។ ជាក់ស្តែង CGCC បានបម្រុងបុគ្គលិកជំនាញ ដើម្បីត្រៀមផ្តល់ការគាំទ្រចាំបាច់នានា ជូនដល់អ្នកប្រើប្រាស់។ ការដាក់ឱ្យដំណើរការ GMS គឺជាសមិទ្ធផលដ៏សំខាន់ ក្នុងការបង្កើនការជឿទុកចិត្ត របស់ភាគីពាក់ព័ន្ធមកលើ CGCC។ ការគាំទ្រពីក្រុមប្រឹក្សាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅលើការវិនិយោគរបស់ CGCC លើការអភិវឌ្ឍ GMS គឺជាភស្តុតាង សបញ្ជាក់បន្ថែមទៀតថា CGCC នឹងមានវត្តមានយូរអង្វែងទៅថ្ងៃអនាគត សម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ៕



## Understanding the Guarantee Management System of CGCC

**By: Mr. Moung Sokbou, Director of IT Services Department**

EN A business cannot grow to its full potential without technology. CGCC is not an exception. "Information technology and business are becoming inextricably interwoven. I don't think anyone can talk meaningfully about one without talking about the other", said Bill Gates, founder of Microsoft. Since the first day of its operation, CGCC has embraced information technology, starting with the basic functions of Excel spreadsheets and Microsoft SharePoint to manage credit guarantee operations. Today, CGCC hit a new milestone by launching the Guarantee Management System (GMS) to further leverage information technology for effective credit guarantee operation. Technology adoption is our commitment to play a small part in supporting the key priorities – People, Road, Water, Electricity, and Technology – of the "Pentagonal Strategy – Phase I" of the new Royal Government of Cambodia.

### *What is GMS?*

GMS is a digital platform that automates and streamlines the credit guarantee process, making it more convenient, faster, and more secure. It is the first-ever and only digital platform to manage a credit guarantee operation in Cambodia, tailored explicitly to CGCC's credit guarantee model. It is a web-based system developed using microservices architecture and modern technologies to improve the guarantee process's efficiency, accuracy, and security.

### *How was GMS developed?*

CGCC has developed the GMS in phases. It took about two years to build the GMS Phase 1 by a team of experienced software developers. The system development is based on an agile approach, with regular feedback from users being incorporated into the system. The GMS has also been carefully developed and extensively tested to ensure it is secure and reliable. In this Phase 1, the GMS offers key attributes as below:

- ***End-to-end automation:*** The GMS automates the guarantee application process, from PFI's submission to CGCC's approval. Auto validation of CGCC's scheme features is integrated to reduce error and time consumption when composing and reviewing the guarantee application.
- ***Real-time tracking:*** The GMS provides real-time monitoring of the status of all guarantee applications, allowing users to stay updated on the progress of each application and request.
- ***Comprehensive reporting:*** The GMS provides comprehensive reporting on all credit guarantee activities, allowing users to track the performance of guaranteed loans and identify areas for improvement.
- ***High security:*** The GMS is hosted on a secure platform and uses the latest security technologies to protect user data.

### *Benefits of GMS*

Improving productivity is the core principle of CGCC in developing GMS. CGCC expects the GMS to increase the productivity of the credit guarantee by offering benefits to both the PFIs and CGCC as below:

**PFIs**

- ***Easier to access:*** The GMS makes it easier for PFIs to access CGCC's guarantee products by providing a single, centralized platform for submitting and tracking guarantee applications.
- ***Reduce the workload:*** The GMS automates many of the manual tasks involved in the guarantee application process, including early guaranteed loan settlement, cancellation or amendment, and guaranteed loan monthly reports, etc.
- ***Speed up the process:*** The GMS significantly reduces the time taken to process guarantee applications. This means that PFIs can disburse guaranteed loans quickly.
- ***Reduce the risk of fraud:*** The GMS includes a number of features to help reduce the risk of fraud, such as user authentication and data encryption.

**CGCC**

- ***Efficiency Boost:*** The automated process significantly streamlines the guarantee workflow, reducing processing times and allowing for more rapid approvals of guarantee applications.
- ***Enhanced Accuracy:*** By minimizing manual data entry and human errors, the GMS ensures accurate and reliable guarantee processing.
- ***Simplified Collaboration:*** The GMS facilitates seamless communication between CGCC and PFIs, fostering a collaborative environment for efficient problem-solving.
- ***Improve the customer experience:*** The GMS makes it easier for PFIs to access CGCC's guarantee products and services.

### *What is next?*

GMS is open for future expansion in terms of functionality and scope. CGCC is committed to continuously improving the GMS to align with CGCC's business development. In the short term, the GMS will be developed to cover an end-to-end process of individual and portfolio guarantee schemes. Moreover, the CGCC will study the feasibility of integrating the GMS with other systems, i.e., with the PFI systems, to make it even easier for PFIs to submit guarantee applications, and with the Credit Bureau of Cambodia (CBC) system further to improve the guaranteed loan monitoring.

Indeed, CGCC does not expect the GMS to function without any hiccups, especially during this initial stage. There will be bugs, errors, and interruptions to be fixed on an ongoing basis. In fact, CGCC has designated an IT professional to provide all necessary support required by our users. The launch of GMS is an important milestone to build the trust of relevant stakeholders in CGCC. Strong support from the Board of Directors and Ministry of Economy and Finance for CGCC's investment in GMS is a testament to confirming that CGCC is here to stay for the long haul for the development of SMEs and the improvement of financial inclusion.

# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC | Meet the Business Owner Who Received a Loan Guaranteed by CGCC

**លោក ជួ មករា ប្រធានសហភាពសហគមន៍បន្លែសុវត្ថិភាពកម្ពុជា | Mr. Chua Makara, Founder of Cambodia Safety Vegetable Union of Agricultural Corporative**





KH វិស័យកសិកម្ម គឺជាវិស័យស្នូលមួយ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា។ ដោយសារមើលឃើញពីសក្តានុពល និងដើម្បីលើកស្ទួយដល់ផលិតផលខ្មែរ និងទ្រទ្រង់ដល់បងប្អូនកសិករខ្មែរ ខ្ញុំបានសម្រេច ចិត្តចាប់ផ្តើមបង្កើតជាសហភាព សហគមន៍បន្លែសុវត្ថិភាពនៅក្នុងឆ្នាំ២០២១។

ចាប់ពេលពីចាប់ផ្តើមដំបូងរហូតដល់សព្វថ្ងៃ បញ្ហាប្រឈមសំខាន់របស់ខ្ញុំគឺ កង្វះធនធានមនុស្សក្នុងការរៀបចំឯកសារ និងការងាររដ្ឋបាលផ្សេងៗដោយសារភាគច្រើនសមាជិកនៅក្នុងសហភាពសហគមន៍គឺជាកសិករ។ បញ្ហាប្រឈមសំខាន់មួយទៀតគឺ កង្វះទុនបង្វិល ដើម្បីពង្រីកអាជីវកម្ម និងជំរុញការនាំចេញ។ ដំណោះស្រាយសម្រាប់ខ្ញុំ គឺប្រាក់កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុ។

ដំបូងឡើយ ដោយសារទ្រព្យធានារបស់ខ្ញុំមិនគ្រប់គ្រាន់ ខ្ញុំមិនទទួលបានប្រាក់កម្ចីតាមតម្រូវការនោះទេ ដែលបានធ្វើឱ្យអាជីវកម្មរបស់ខ្ញុំមានការរាំងស្ទះ។ ប៉ុន្តែក្រោយមក ដោយសារការធានាឥណទានពី CGCC ខ្ញុំក៏ទទួលបានកម្ចីអាជីវកម្មពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន តាមទំហំកម្ចីដែលខ្ញុំបានស្នើសុំទាន់ពេលវេលា។ បន្ទាប់ពីទទួលបានកម្ចីដែលមានការធានា ខ្ញុំបានយកវាទៅធ្វើជាទុនបង្វិល ដែលអាចឲ្យខ្ញុំបន្តការអាជីវកម្មសហភាពសហគមន៍បន្លែសុវត្ថិភាព ជូនដល់អតិថិជន និងដេប៉ូចែកចាយបានជាច្រើនខេត្តក្រុងទាន់ពេលវេលា។ មិនតែប៉ុណ្ណោះអាជីវកម្មរបស់ខ្ញុំ ក៏ទទួលបានការជឿទុកចិត្តពីដៃគូរអភិវឌ្ឍន៍នានាផងដែរ។

ការទទួលបានកម្ចីដែលមានការធានាពី CGCC គឺអាស្រ័យទៅលើសក្តានុពលនៃអាជីវកម្មរបស់ខ្ញុំពោលគឺ លទ្ធភាពនៃការរីកចម្រើនទៅមុខ ការកសាងនិងការថែទាំប្រវត្តិឥណទានឲ្យបានល្អ ក៏ដូចជាការបំពេញឯកសារតម្រូវដែលអាចបញ្ជាក់ពីភាពចាំបាច់ក្នុងការប្រើប្រាស់កម្ចីសម្រាប់អាជីវកម្មរបស់ខ្ញុំ។ ម្ចាស់អាជីវកម្មដទៃទៀតដែលមានតម្រូវការទុនប៉ុន្តែខ្វះទ្រព្យធានា ក៏អាចស្វែងរកការធានាឥណទានពី CGCC តាមរយៈគ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុជាដៃគូរបស់ CGCC បានដែរ៕

EN Agriculture is one of the key sectors in supporting Cambodia's economic growth. Seeing the potential to promote Cambodian products and support Cambodian farmers, I decided to start a Cambodia Safety Vegetable Union of Agricultural Cooperative in 2021.

When starting this business, my main challenge was the lack of human resources to prepare documents and handle administrative work since most of the community union members were farmers. Another major challenge was the lack of working capital to expand the business and product exports. The solution for me was a loan from a financial institution.

At first, because my collateral was not enough for the loan, I could not obtain the necessary loans to support my business. However, later with a guarantee from CGCC, I was able to receive a sufficient business loan from Chamroeun Microfinance Institution. I used the guaranteed loan as a working capital, which allowed me to grow my Cambodia Safety Vegetable business to serve my customers and distributors in many provinces and cities on time. I also gained the trust of various development partners on my business.

Obtaining a guaranteed loan from CGCC depends on the potential of my business, namely the possibility of growth, building a good credit history, as well as completing the required documents that can confirm the need to use a loan for my business. Other business owners who need capital but lack collateral can also seek credit guarantees from CGCC through CGCC partner banks or microfinance institutions.

# ការស្វែងយល់អំពីការធានាឥណទានរបស់តៃវ៉ាន់ | Understanding about Taiwan Credit Guarantee

**ដោយ៖ លោក គី ហុង បុគ្គលិកជំនាញផ្នែកអភិវឌ្ឍផលិតផល | By: Mr. Ky Hong, Executive of Product Development**




KH នៅឆ្នាំ ១៩៧៤ មូលនិធិធានាឥណទានសហគ្រាសធុនតូច និងមធ្យម តៃវ៉ាន់ (Small & Medium Enterprise Credit Guarantee Fund of Taiwan - SMEG) ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញដើម្បីគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលតាមរយៈការផ្តល់ការធានាឥណទានដល់សហគ្រាសធុនតូច និង មធ្យម ដែលមិនមានទ្រព្យធានាគ្រប់គ្រាន់ឱ្យមានលទ្ធភាពទទួលបានកម្ចីពីស្ថាប័នហិរញ្ញវត្ថុ។ ក្នុងឆ្នាំ ២០២៣ នេះ SMEG មានគោលបំណងគាំទ្រដល់គោលដៅអភិវឌ្ឍន៍ជាតិ ដោយអភិវឌ្ឍគម្រោងធានាឥណទាន ដែលផ្តោតលើដំណើរឆ្ពោះទៅរក Net-Zero Emissions នៅក្នុងឆ្នាំ ២០៥០ របស់តៃវ៉ាន់ (Taiwan's Pathway to Net-Zero Emissions in 2050) រួមមានកម្មវិធីលើកកម្ពស់យុទ្ធសាស្ត្រឧស្សាហកម្មស្នូលទាំង៦, ធុរកិច្ចបង្កើតថ្មី និងអាជីវកម្មខ្នាតមីក្រូ, បរិវត្តកម្មឌីជីថល និងថាមពល, និងការអភិវឌ្ឍបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។

ប្រភពមូលនិធិរបស់ SMEG ភាគច្រើនទទួលបានមកពីការផ្តល់ឱ្យដោយរដ្ឋាភិបាលកណ្តាល រដ្ឋបាលមូលដ្ឋាន និងស្ថាប័នហិរញ្ញវត្ថុដៃគូ។ ដោយក្នុងនោះ ៧០% គឺបានមកពី រដ្ឋាភិបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន ហើយ ៣០% ទៀតបានមកពីស្ថាប័នហិរញ្ញវត្ថុដែលជាដៃគូ។ គិតត្រឹមខែសីហា ឆ្នាំ២០២៣ SMEG បានជួយគាំទ្រ SME ចំនួន ២,៣លាន ដោយបានផ្តល់នូវការធានាឥណទានចំនួន ១០,៦ លានករណី ជាមួយនឹងទំហំនៃការធានាសរុបប្រមាណជា ៧៧៥ ប៊ីលានដុល្លារ។

បច្ចុប្បន្ន SMEG ផ្តល់ការធានាឥណទានបីប្រភេទ រួមមាន ការធានាឥណទានដោយប្រយោល, ការធានាឥណទានដោយផ្ទាល់, និងការធានាឥណទានរួមគ្នា។ ការធានាឥណទានដោយប្រយោលត្រូវបានបង្កើតឡើងដើម្បីអនុញ្ញាតឱ្យ ស្ថាប័នហិរញ្ញវត្ថុដៃគូរអាចស្នើសុំការធានាឥណទានមកកាន់ SMEG លើកម្ចីរបស់ SME ដែលមិនមានទ្រព្យធានាគ្រប់គ្រាន់។

សម្រាប់ការធានាឥណទានដោយផ្ទាល់ SME ដែលស្ថិតនៅក្នុងវិស័យ នៃការស្រាវជ្រាវ និងអភិវឌ្ឍន៍, ការគ្រប់គ្រងអាជីវកម្ម ឬ ការអភិវឌ្ឍទីផ្សារ អាចធ្វើការស្នើសុំលិខិតធានាឥណទានពី SMEG ដើម្បីស្នើសុំកម្ចីពីស្ថាប័នហិរញ្ញវត្ថុ។ ចំពោះការធានាឥណទានរួមគ្នា SME អាចធ្វើការស្នើសុំលិខិត (Letter of Recommendation) ពីស្ថាប័នដែលជាម្ចាស់ជំនួយ ហើយបន្ទាប់មកស្នើសុំទៅស្ថាប័នហិរញ្ញវត្ថុដៃគូ និង SMEG សម្រាប់កម្ចីឥណទាន និងការធានាឥណទាន។

EN In 1974, the Small and Medium Enterprises Credit Guarantee Fund of Taiwan (Taiwan SMEG) was established as a non-profit organization to support the government's financial and economic policies by providing credit guarantees to SMEs that are short of collateral to be able to access formal loans from the financial institutions. In 2023, the Taiwan SMEG aims to support the national development goals by focusing its guaranteed schemes on Taiwan's Pathway to Net-Zero Emissions in 2050, Program for Promoting Six Core Strategic Industries, startups and micro-SMEs, digital and energy transformation, and development of ESG.

The Taiwan SMEG's source of funds is mainly donations from the Central Government, Local Government, and contracted Financial Institutions (FIs). 70% of the donation is from the Central Government and Local Government, while the remaining 30% is from contracted FIs. As of August 2023, SMEG Taiwan supported 2.3 million SMEs by providing 10.6 million guaranteed cases with Guaranteed Loans of USD 775 billion equivalent.

Currently, Taiwan SMEG provides three types of Guarantee Procedures: Indirect Guarantee, Direct guarantee, and Co-guarantee. The Indirect Guarantee is developed to allow contracted FIs to submit credit guarantee requests to Taiwan SMEG for SMEs that are short of collateral. For the Direct Guarantee, SMEs with R&D capacity, business management, or market development can apply for a Letter of Commitment from Taiwan SMEG to be used as a guarantee to apply for loans from FIs. In the Co-guarantee, the SMEs could apply for a Letter of Recommendation from the donating institution and then apply to the FIs and SMEG for loan and credit guarantees.

Source: https://www.smeg.org.tw/en/

# CGCC នៅលើសារព័ត៌មាននានា | CGCC on the News




### NBC sets new capital, and risk rules for banks, financial institutions

News article in English from Khmer Times, published on 04 July 2023 https://bit.ly/46UQiVN




### CGCC and Canadia Bank partner for quick loan turnaround

អត្ថបទព័ត៌មានជាភាសាខ្មែរពីសារព័ត៌មាន Business Cambodia & Fresh News ចេញផ្សាយថ្ងៃទី២៥ កក្កដា ឆ្នាំ២០២៣ https://bit.ly/471P7DW

News article in English from The Phnom Penh Post, published on 19 July 2023 https://bit.ly/48m8j0B




### Wing Bank, CGCC, and FASMEC to Offer Guaranteed Loans and Market Accessibility to SMEs

អត្ថបទព័ត៌មានជាភាសាខ្មែរពីសារព័ត៌មាន Business Cambodia & Fresh News ចេញផ្សាយថ្ងៃទី២៦ សីហា ឆ្នាំ២០២៣ https://bit.ly/3QrX7HJ

News article in English from Khmer Times, published on 23 August 2023 https://bit.ly/45Qzw8Z




### CGCC accredited as Cambodia's first bond issuance guarantor

News article in English from The Phnom Penh Post, published on 11 September 2023 https://bit.ly/3QDqFmS



### CGCC provides $130M credit guarantees to over 1,500 businesses

News article in English from The Phnom Penh Post, published on 20 July 2023 https://bit.ly/46aVGmR



### CGCC gets Honorable Mention in Global Finance SME Award 2023

News article in English from Khmer Times, published on 26 September 2023 https://bit.ly/3tLMZ4L

## ផលិតផលឥណទានដែលមានការធានាពី CGCC របស់ PFIs | Guarantee Product from Our PFIs

PhillipBank




### ឥណទានខ្នាតតូច

ឥណទានខ្នាតតូច ជាប្រភេទឥណទានមានកាលកំណត់ដែលធនាគារ ហ្វីលីព ផ្តល់ជូនដល់អតិថិជនឯកត្តជនសម្រាប់៖

- កសិកម្ម ៖ ការចំណាយលើសកម្មភាពនានាក្នុងវិស័យកសិកម្ម ទិញសម្ភារៈកសិកម្ម ការបង្កបង្កើនផល ឬសកម្មភាពអាជីវកម្មដែលរកប្រាក់ចំណូលតាមរដូវកាល។
- អាជីវកម្ម៖ ការចាប់ផ្តើម ឬពង្រីកអាជីវកម្ម បង្កើនស្តុក ឬដើមទុនអាជីវកម្ម និងបង់ផ្តាច់ប្រាក់កម្ចីដែលមានស្រាប់ជាដើម។
- ប្រើប្រាស់ទូទៅ៖ ចំណាយលើការទិញរបស់របរប្រើប្រាស់ ករណីបន្ទាន់សម្ភារៈ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬនៅក្នុងក្រុមគ្រួសារ។
- កែលម្អគេហដ្ឋាន៖ សម្រាប់សាងសង់ ឬកែលម្អគេហដ្ឋាន រៀបចំប្រព័ន្ធទឹកស្អាត អនាម័យ និងទិញដី ឬគេហដ្ឋានស្របតាមស្តង់ដាររស់នៅដែលលោកអ្នកប្រាថ្នា។
- សម្រាប់ការសិក្សា៖ ជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលដែលចង់បន្តការសិក្សាថ្នាក់ឧត្តមសិក្សា ឬជំនាញបច្ចេកទេសដូចជា៖ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬវគ្គបំប៉នផ្សេងៗ។

| លក្ខណៈពិសេស | |
|---|---|
| ទំហំឥណទាន | ១០០.០០០រៀល - ២៨០ លានរៀល<br>១០០ ដុល្លារ - ៧០.០០០ ដុល្លារ |
| អត្រាការប្រាក់ប្រចាំខែ | ១,១% - ១,៥% |
| រយៈពេលកម្ចី | រហូត ១២០ខែ |
| វិធីសាស្ត្របង់សង | ការបង់សងមានច្រើនជម្រើស និងបត់បែន |
| អនុគ្រោះទូទាត់ប្រាក់ដើម | រហូតដល់ ៦ខែ |

**លក្ខខណ្ឌ៖**

- អាយុចន្លោះពី ១៨ ទៅ ៦៥ ឆ្នាំ។
- ជាជនជាតិកម្ពុជាដែលមានអាជីវកម្មផ្ទាល់ខ្លួន ឬជានិយោជិកមានប្រាក់ខែ ហើយរស់នៅក្នុងតំបន់ប្រតិបត្តិការរបស់ធនាគារ ហ្វីលីព
- ជាអាជីវកម្មស្របច្បាប់ (មិនប៉ះពាល់ដល់បរិស្ថាន ឬសង្គម)

**ឯកសារតម្រូវ៖**

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនមានសុពលភាព
- ប័ណ្ណសម្គាល់ខ្លួនបុគ្គលិក (បើមាន)
- វិញ្ញាបនប័ត្រប្រកបអាជីវកម្ម (បើមាន)
- ឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ (បើមាន)

*ធនាគារ សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌមួយចំនួនដោយមិនចាំបាច់ជូនដំណឹងជាមុន។

**សេវាបម្រើអតិថិជន**
086 930 000
089 989 818
088 465 9999

**ទំនាក់ទំនង**
PhillipBank Cambodia
info@phillipbank.com.kh
www.phillipbank.com.kh

ចម្រើន

ឥណទានសហគមន៍កសិកម្ម ត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ហិរញ្ញប្បទានដល់សហគមន៍ សម្រាប់ធ្វើប្រតិបត្តិការក្នុងផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម សេវាកម្មពាក់ព័ន្ធ និងទុនបង្វិល និងវិនិយោគលើទ្រព្យសកម្មផ្សេងៗទៀត។




**លក្ខណៈពិសេស និងអត្ថប្រយោជន៍របស់ផលិតផលឥណទាន៖**

- ទំហំឥណទាន៖ រហូតដល់ ៧៥.០០០ដុល្លារ ឬសមមូលជាប្រាក់រៀល
- អត្រាការប្រាក់ប្រចាំខែ: ០,៩៥% ទៅ ១,៣៥%

- រយៈពេលកម្ចី៖ រហូតដល់៦០ខែ
- របៀបបង់សង៖ បត់បែនតាមលំហូរសាច់ប្រាក់អាជីវកម្មរបស់អតិថិជន
- ទ្រព្យធានា៖ ករណីមិនមានទ្រព្យធានាគ្រប់គ្រាន់ អតិថិជនអាចទទួលបានការធានាពី CGCC ដើម្បីទទួលបានឥណទានអាជីវកម្ម។

**តម្រូវការ/លក្ខខណ្ឌ៖**

- វិញ្ញាបនបត្រចុះបញ្ជី (ច្បាស់ចម្លង)
- ឯកសារអត្តសញ្ញាណអ្នកចុះហត្ថលេខាលើកិច្ចសន្យាខ្ចីប្រាក់ (ច្បាប់ចម្លង)
- កំណត់ហេតុសន្និបាតចុងក្រោយ
- របាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល

ឥណទានអាជីវកម្មពិសេសផ្ដល់ជូនសម្រាប់សហគ្រិនស្ត្រី (០១-កញ្ញា-២០២៣ ដល់ ២៩-កុម្ភៈ-២០២៤)

តើអ្នកកំពុងខិតខំប្រឹងប្រែង ដើម្បីសម្រេចគោលដៅអាជីវកម្មរបស់អ្នក ហើយមានតម្រូវការចរិកាបន្ថែមមែនទេ? យើងផ្ដល់ជូននូវអត្ថប្រយោជន៍ពិសេសសម្រាប់លោកអ្នក! ឥណទានអាជីវកម្មរបស់យើងផ្ដល់ជូន និងស្វាគមន៍សហគ្រិនស្ត្រីគ្រប់រូប។ លោកអ្នកអាចទទួលបានប្រាក់កម្ចីរហូតដល់១០០.០០០ ដុល្លារ ដោយគ្មានទ្រព្យធានា។

**លក្ខណៈពិសេស៖**

- ទំហំឥណទាន៖ ច្រើនបំផុតរហូតដល់ ១០០.០០០ ដុល្លារ ឬសមមូលនឹងប្រាក់រៀល
- រយៈពេលឥណទាន៖ រហូតដល់ ៦ឆ្នាំ
- ទ្រព្យធានា៖ មិនតម្រូវឱ្យមាន
- អត្រាការប្រាក់៖ ០,៩៥% ទៅ ១,៣៥%

| ឆ្នាំទី១ | ចាប់ពីឆ្នាំ |
|---|---|
| ៧,៥% ក្នុងមួយឆ្នាំ (រៀល) | អត្រាការប្រាក់ស្តង់ដារបស់ធនាគារ |
| ៨,៥% ក្នុងមួយឆ្នាំ (រៀល) | |

- សេវាអនុម័តឥណទាន៖ ១%
- ថ្លៃសេវាផ្សេងៗ៖ អាស្រ័យលើករណីជាក់ស្ដែង

លក្ខខណ្ឌក្នុងការស្នើ៖ ស្ត្រី ឬសហគ្រាសខ្នាតតូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រី ដែលមានលក្ខណៈសមស្របតាមលក្ខខណ្ឌខាងក្រោមយ៉ាងតិចពីរចំណុច៖

- ស្ត្រីដែលជាម្ចាស់ភាគហ៊ុនធំ
- អ្នកគ្រប់គ្រង ឬអ្នកធ្វើការសម្រេចចិត្តលើអាជីវកម្ម គឺជាស្ត្រី
- ស្ត្រីតំណាងឱ្យក្រុមហ៊ុនលើការចុះបញ្ជីអាជីវកម្មស្របច្បាប់ណាមួយ
- មានបុគ្គលិកភាគច្រើនជាស្ត្រី
- អាចស្នើបានទាំងអតិថិជនមានស្រាប់ និងអតិថិជនថ្មី

**លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត។*



## PFIs របស់ CGCC ដែលបានស្នើសុំការធានាឥណទានកន្លងមក | Our Active PFIs

**ACLEDA BANK**
Tel: 023 998 777
Email: acledabank@acledabank.com.kh
Web: www.acledabank.com.kh

**APD BANK** – ASIA-PACIFIC DEVELOPMENT BANK
Tel: 023 211 888
Email: ccc@apdbank.com.kh
Web: www.apdbank.com.kh

**CAMBODIAN PUBLIC BANK**
Tel: 023 428 100
Email: CustomerService@campubank.com.kh
Web: www.campubank.com.kh

**CAB BANK** – CAMBODIA ASIA BANK
Tel: 023 980 000
Email: sale@cab.com.kh
Web: www.cab.com.kh

**CAMBODIA POST BANK PLC.**
Tel: 023 260 888
Email: info@cambodiapostbank.com
Web: www.cambodiapostbank.com

**CANADIA BANK**
Tel: 023 868 222
Email: contact@canadiabank.com.kh
Web: www.canadiabank.com.kh

**CIMB BANK**
Tel: 023 988 388
Email: customercare@cimb.com.kh
Web: www.cimbbank.com.kh

**FTB** – Foreign Trade Bank of Cambodia
Tel: 023 862 111
Email: info@ftbbank.com
Web: www.ftbbank.com

**Maybank**
Tel: 098 888 028
Email: contactus.mcp@maybank.com
Web: www.maybank2u.com.kh

**Oriental Bank**
Tel: 023 932 288
Email: customerservice@orientalbank.com.kh
Web: www.orientalbank.com.kh

**PhillipBank**
Tel: 086 930 000
Email: info@phillipbank.com.kh
Web: www.phillipbank.com.kh

**RHB**
Tel: 023 992 833
Email: hello@rhbgroup.com
Web: www.rhbgroup.com.kh

**SATHAPANA BANK**
Tel: 023/081 992 010
Email: customercare@sathabana.com.kh
Web: www.sathapana.com.kh

**ABA BANK**
Tel: 023 225 333
Email: info@ababank.com
Web: www.ababank.com

**AMK**
Tel: 023 220 202
Email: customerservice@amkcambodia.com
Web: www.amkcambodia.com

**BRED BANK CAMBODIA**
Tel: 1800 20 1234
Email: contact@bredcambodia.com
Web: www.bredcambodia.com

**CAMMA MICROFINANCE**
Tel: 023 533 9999
Email: info@camma.com.kh
Web: www.camma.com.kh

**CHIP MONG BANK**
Tel: 081 811 911
Email: info@chipmongbank.com
Web: www.chipmongbank.com/ en

**Chamroeun**
Tel: 023 959 777
Email: info@chamroeun.com
Web: www.chamroeun.com

**J Trust Royal Bank**
Tel: 023 999 000
Email: ccc@jtrustroyal.com
Web: www.jtrustroyal.com

**LOLC**
Tel: 023 991 991
Email: info@lolc.com
Web: www.lolc.com.kh

**PRINCE BANK**
Tel: 1800-20-8888
Email: info@princebank.com.kh
Web: www.princebank.com.kh

**Wing**
Tel: 023 999 0989
Email: care.centre@wingmoney.com
Web: www.wingmoney.com

បើលោកអ្នកមានជាមតិយោបល់ដើម្បីកែលម្អ ព្រឹត្តិបត្រព័ត៌មានរបស់ CGCC សូមទំនាក់ទំនង មកក្រុមការងាររបស់យើងខ្ញុំតាមរយៈ

023 722 123 | Info@cgcc.com.kh

# បង្កើនបរិយាបន្នហិរញ្ញវត្ថុនិង អភិវឌ្ឍ សហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា

## Improve Financial Inclusion and Develop SMEs in Cambodia


023 722 123

info@cgcc.com.kh

www.cgcc.com.kh

សាជីវកម្មធានាឥណទានកម្ពុជា
Credit Guaranteen Corporation
of Cambodia

សាជីវកម្មធានាឥណទានកម្ពុជា CGCC

Credit Guaranteen Corporation of
Cambodia (CGCC)

Business Development Center, 19th Floor, OCIC Blvd,
Sangkat Chroy Changvar, Khan Chroy Changvar,
Phnom Penh, Cambodia

www.cgcc.com.kh